**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ១៩៧២ សជណ

ថ្ងៃ ...១២ រោច... ខែ ...កត្តិក... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ...១៩... ខែ ...វិច្ឆិកា... ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់ ម៉ាស៊ីនបូមទឹកដាក់រថយន្តពន្លត់អគ្គិភ័យ និងសម្ភារបង្ការពន្លត់អគ្គិភ័យ ជូនស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម, បាត់ដំបង, កណ្តាល, បន្ទាយមានជ័យ, កំពត, កំពង់ធំ, កំពង់ឆ្នាំង, ព្រះវិហារ, កោះកុង, ប៉ៃលិន, តាកែវ និងស្វាយរៀង

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា : ក្រសួងមហាផ្ទៃ នឹងដាក់ឱ្យដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ដើម្បីជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ ម៉ាស៊ីនបូមទឹកដាក់រថយន្តពន្លត់អគ្គិភ័យ និងសម្ភារបង្ការពន្លត់អគ្គិភ័យ ជូនស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម, បាត់ដំបង, កណ្តាល, បន្ទាយមានជ័យ, កំពត, កំពង់ធំ, កំពង់ឆ្នាំង, ព្រះវិហារ, កោះកុង, ប៉ៃលិន, តាកែវ និងស្វាយរៀង ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារដេញថ្លៃ (សៀវភៅបន្ទុក) សម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋានស្ថិតនៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ...២៧... ខែ...វិច្ឆិកា... ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៩៧ ៦៦ ៧៧ ៨៥៦) ។

ឯកសារដេញថ្លៃ (សៀវភៅបន្ទុក) ដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតត្រឹមវេលាម៉ោង...៩:៣០...នាទី ថ្ងៃទី...១២... ខែ...ធ្នូ...ឆ្នាំ២០១៨ ។

ការបើកកញ្ចប់ឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង...៩:៣០...នាទី ថ្ងៃទី...១២... ខែ...ធ្នូ...ឆ្នាំ២០១៨ ។

-ក្រុមហ៊ុន ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

-ក្រុមហ៊ុនត្រូវភ្ជាប់ជាមួយនូវឯកសារ ដែលមានចែងក្នុងប្រការ៣ នៃឯកសារដេញថ្លៃនៅពេលដាក់ពាក្យសុំទិញឯកសារដេញថ្លៃ ។

-ចំពោះក្រុមហ៊ុន ដែលមានបំណងចូលរួមដេញថ្លៃត្រូវមកទទួល និងដាក់ពាក្យសុំទិញឯកសារនៅអង្គភាពលទ្ធកម្ម ស្ថិតនៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី២៧ខែ...វិច្ឆិកា...ឆ្នាំ២០១៨ ដល់ថ្ងៃទី...០៣... ខែ...ធ្នូ..... ឆ្នាំ២០១៨ ។ រាល់ពាក្យសុំចូលរួមដេញថ្លៃរបស់បណ្តាក្រុមហ៊ុន នឹងត្រូវដាក់ជូនគណៈកម្មាធិការលទ្ធកម្ម ពិនិត្យ និងវាយតម្លៃអំពីលក្ខណសម្បត្តិរបស់ក្រុមហ៊ុន និងសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គលម** មុនលក់ឯកសារដេញថ្លៃ (សៀវភៅបន្ទុក) ជូនក្រុមហ៊ុន ដែលមានបំណងចូលរួមដេញថ្លៃ និងដាក់ឯកសារដេញថ្លៃតាមកាលបរិច្ឆេទខាងលើ ។

-ក្រុមហ៊ុន ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារដេញថ្លៃ (សៀវភៅបន្ទុក) និងសាកសួរព័ត៌មាននានាដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធាន គលម**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"